ឧបសៅសង្ហា

# ព្រះធម្មរាជា (១៤៧៨-១៥០៤)




## ពិនិត្យឡើងវិញនូវព្រឹត្តិការណ៍សំខាន់ៗមាននៅក្នុង ប្រវត្តិសាស្ត្រខ្មែរ

**សង្ខេប សម្រួល ដកស្រង់ ពី ឯកសារ លោក អេង សុត និង អធិប្បាយ ជា មតិផ្ទាល់**

**មាតិការឿង**

អារម្ភកថា ........ 2
ព្រឹត្តិការណ៍ ........ 4
អត្ថធិប្បាយ ........ 21
សេចក្តីសន្និដ្ឋាន ........ 31

# អារម្ភកថា

អត្ថបទ នេះ ខ្ញុំ ធ្លាប់ បាន ចុះផ្សាយ នៅ ក្នុង ប្លុក (Overblog) របស់ ខ្ញុំ នៅ ឆ្នាំ ២០១៤ ជា ពីរ ជំពូក ដាច់ គ្នា ទី១ នៅ ខែ មករា ទី២ នៅ ខែ កុម្ភៈ ក្នុង ទំហំ អក្សរ តូច នាំ អោយ អ្នកអាន ពិបាក អាន ព្រោះ នៅ ឆ្នាំ នោះ ប្លុក របស់ខ្ញុំ គេ មិន អនុញ្ញាត អោយ ចុះ ផ្សាយ ហួស ពី ២០ ទំព័រ ក្នុង ការចុះផ្សាយ មួយដងៗ។ ឥឡូវ នេះ ប្លុក នេះ គេ អាច អោយ ចុះផ្សាយ អត្ថបទ ក្នុង ទំហំ Pdf ដោយ មិន កំរិត ចំនួន ទំព័រ ; អាស្រ័យហេតុនេះ ដើម្បី សំរួល ក្នុង ការអាន ខ្ញុំ យក ជំពូក ទាំង ពីរ នេះ មក បង្រួប តែ មួយ ហើយ ប្រើ ខ្នាត អក្សរ ធំ។

ការពិនិត្យ ឡើងវិញ នូវ ព្រឹត្តិការណ៍ សំខាន់ៗ មាន នៅ ក្នុង ប្រវត្តិសាស្ត្រខ្មែរ ដោយ យក ឯកសារ ស្រាវជ្រាវ ដោយ លោក អេង សុត[1] ជា យោង គឺ គ្មាន បំណង ចង់ ជំទាស់ នឹង ប្រវត្តិសាស្ត្រ ជា ផ្លូវការ របស់ ប្រជាជាតិខ្មែរ នោះ

[1] ឯកសារ មហាបុរសខ្មែរ-ព្រះរាជពង្សាវតាខ្មែរ។ លោក អេង សុត ជា សមាជិក នៃ គណកម្មការ ប្រវត្តិសាស្ត្រ និង វប្បធម៌ ខ្មែរ។ លោក មាន អាជីព ជា ចៅក្រមប្រឹក្សា សាលាវិនិច្ឆ័យ។ ឯកសារ នេះ លោក បាន ចុះ ផ្សាយ នៅ ទស្សវត្សរ៍ ៧០។ ឯកសារ នេះ ជា ព្រះរាជពង្សាវតា សុទ្ធសាធ ដែល បុព្វបុរស ខ្មែរយើង លោក បាន សរសេរ ទុក ក្នុង ក្រាំង ក៏ មាន ខ្លះ ចារ លើ ស្លឹករិត ក៏ មាន ខ្លះ ដើម្បី ទុក ជា កេរ្ត៍ អោយ បច្ឆាជន ដែល កើត ក្រោយ បានដឹង ជាតិកំណើត នៃ ប្រទេស របស់ខ្លួន អោយ បាន ជាក់ ច្បាស់ផង។

ឡើយ តែ គ្រាន់ តែ យក ព្រឹត្តិការណ៍ ប្រវត្តិសាស្ត្រ មក ពិចារណា ជា បញ្ញាភា ស្វែងរក ឧប្បត្តិដ្ឋាន (origine) នៃ អង្គហេតុ ដើម្បី យល់ដឹង អំពី ហេតុផល របស់ វា។ តែ កិច្ចការ នេះ ក៏ ខ្ញុំ មិន ទុក ជា វិចយ (investigation) ដើម្បី រក ការពិត ដាច់ខាត នោះដែរ វា គ្រាន់ តែ ជា កិច្ចការ នៃ គំនិត ថ្មី ដើម្បី ជូន ជា វិស័យមតិ ផ្ទាល់ខ្លួន សំរាប់ បច្ចាជន យក ទៅ វា ពិចារណា ឬ ពិភាក្សា ទៅ តាម ការ យល់ ឃើញ រៀងៗខ្លួន ដើម្បី បំបាន (enrichir) បញ្ញាខ្មែរ។ ដូច្នេះ ការយល់ខុសគ្នា លើ អង្គហេតុ នៃ ព្រឹត្តិការណ៍ ប្រវត្តិសាស្ត្រ មិនមែន ទុក ជា ទំនាស់ រវាង ខ្មែរ នឹង ខ្មែរ នោះ ឡើយ ព្រោះ ខ្មែរយើង មាន មូលដ្ឋាន តែមួយ គឺ សេចក្តីស្នេហាជាតិរួម។ ការខ្វែង យោបល់គ្នា វា នឹងអាច ជា ភាពសម្បូណ៌ នៃ គំនិត ទៅវិញ បើ ខ្មែរយើង យល់ដឹង ច្បាស់ អំពី ប្រយោជន៍ជាតិ នៅ ក្នុង អារម្មណ៍ ជា កូនខ្មែរ មាន វប្បធម៌ ថ្កុំថ្កើង។

ក្នុង ការសាកល្បង ពិចារណា នេះ ដែល មិនមែន ជា ការ វិនិច្ឆ័យ តែ គ្រាន់ តែ ជា ការវិភាគ បើ សិន មាន ការខុសឆ្គង នៅ ក្នុង គំនិត ផ្ទាល់ របស់ខ្ញុំ សូម អស់ លោក លោកស្រី មេត្តា អភ័យទោស ទុក ជា មុន។

# ព្រឹត្តិការណ៍

ព្រះធម្មរាជា ជា ព្រះរាជ សន្តិណ្ឌបុត្រ (កូនកាត់) ព្រះបាទ ពញាយ៉ាត (១៣៨៣-១៤២៧) ជា មួយ ម្តាយ របស់ ព្រះអង្គ ដែល ជា ជនជាតិសៀម មាន នាម ស៊ី សាងាម ដែល ជា ស្នំឯក ថ្នាក់ ព្រះម្នាង របស់ ព្រះឥន្ទរាជា ដែល ជា រាជបុត្រ ស្តេច សៀម ដែល ព្រះចៅ សៀម ទុក ឲ នៅ គ្រងរាជ្យ ក្នុង នគរ កម្ពុជា បន្ត បន្ទាប់ ពី ព្រះរៀម របស់ ទ្រង់ ពីរ នាក់ មក (ចៅបាសាត និង ចៅកំបង់ពិសី) ក្រោយ ពី ព្រះអង្គ វាយ បាន ស្រុកខ្មែរ ដាក់ ជា ចំណុះ នៅ ឆ្នាំ ១៣៥៣។ ក្រោយ ពី ព្រះឥន្ទរាជា ចាញ់ សង្គ្រាម ហើយស្លាប់ ក្នុង សង្គ្រាមទៅ នៅ មហានគរ ព្រះបាទ ពញាយ៉ាត ជា ស្តេច ឈ្នះ សង្គ្រាម ក៏ សព្វ ព្រះទ័យនឹង អ្នក ស៊ី សាងាម នោះ ណាស់ ស្តេច ទ្រង់យក អ្នកម្នាង នេះ ទុក ជា ព្រះស្នំឯក។ បន្ទាប់ មក ព្រះម្នាង ស៊ី សាងាម បាន ប្រសូត្រ បាន ព្រះ រាជបុត្រ មួយ អង្គ មាន ព្រះនាម ព្រះធម្មរាជា។ ត្រូវ ដឹង ថា ព្រះពញាយ៉ាត ព្រះអង្គ មាន ព្រះរាជបុត្រ បី អង្គ កើត ពី មាតា បី ខុសគ្នា ព្រះនរាយណ៍រាជា ព្រះសេរីរាជា និង ព្រះធម្មរាជា។

ក្រោយ ពី ព្រះពញាយ៉ាត សុគត ទៅ ព្រះរាជបុត្រ ច្បង ព្រះ នរាយណ៍រាជា ត្រូវ បាន ព្រះបរមរាជវង្សានុវង្ស នាម៉ឺន សព្វមុខមន្ត្រី អញ្ជើញ ព្រះអង្គ ឲ ឡើង សោយរាជ្យ ស្នង

ព្រះបីតា។ លុះ ព្រះអង្គ សោយរាជ្យ បាន ៦ ព្រះវស្សា ព្រះជន្ម ៣៩ ឆ្នាំ ទ្រង់ ប្រឈួន ជា ទម្ងន់ ហើយ សុគត ទៅ។ ព្រះបរមរាជវង្សានុវង្ស នាម៉ឺនសព្វមុខមន្ត្រី ក៏ នាំ គ្នា អញ្ជើញ ព្រះសេរីរាជា ជា ព្រះអនុជ បន្ទាប់ ៤ ឡើង សោយរាជ្យ ស្នង ព្រះជេដ្ឋា។ បន្ទាប់ ពី បាន ឡើង សោយរាជ្យ អស់មួយ រយៈពេល មក ទ្រង់ បាន ដំណឹង ថា នៅ ស្រុកសៀម មាន កើត កង្វល់ ព្រោះ យុន វរវង្សា បាន ធ្វើ រដ្ឋប្រហារ ដណ្ដើម រាជ្យ ពី ព្រះចៅ យ៉តហ្វា។ ដំណឹង នេះ នាំ ចិត្ត ព្រះអង្គ ចង់ សងសឹកនឹង នគរ សៀម ដែល តែងតែ លើកទ័ព មក វាយ ស្រុកខ្មែរ ពីរ គ្រា រួច មកហើយ កៀរ គ្រួរខ្មែរ យក ទៅ ជា ច្រើន ព្រោះ ទ្រង់ ឈ្វេងយល់ ថា បើ លើកទ័ព ទៅ វាយ សងសឹក សៀម ក្នុង ពេល នគរ នោះ កំពុងមាន វិវាទ ផ្ទៃក្នុង ហើយ វា ពុំ ទាន់ រៀបទាប នៅឡើយ ប្រាកដ ជា មាន ជ័យជំនះ ជា ពុំ ខាន។

ក្រោយ ពី បាន ពិចារណា ជាមួយ អស់សព្វ មុខមន្ត្រី រួចហើយ ទ្រង់ បាន បញ្ជា ឲ កេណ្ឌ ពល បាន ចំនួន ១២ ម៉ឺននាក់ ហើយ ព្រះអង្គ ដឹកនាំ ទ័ព ផ្ទាល់ ចូល វាយ នគរសៀម ទុក ឲ ព្រះអនុជ ព្រះធម្មរាជា នៅ រក្សា ព្រះនគរ។ ប្រតិបត្តិការសឹក វាយ សម្រុក ចូល ស្រុកសៀម លើក នោះមាន ដំណើរ ប្រកប ដោយ ជោគជ័យ ក្នុង រយៈពេល ដ៏ខ្លីមួយ។ កង ទ័ពហ្លួង បាន វាយ យក ខេត្ត មឿងបស្ទិម

បាន (មឿងប្រាជិម សព្វថ្ងៃ នេះ) ចាប់ បាន ចៅហ្វាយ ខេត្ត និង ក្រុមការសៀម ជា ច្រើន ហើយ ថែម ទាំង កៀរ គ្រួរសៀម បាន ជាង មួយ ពាន់ ប្លាយនាក់ ទៀតផង ឯចំណែក សម្ដេច ចៅហ្វាទឡ្ហៈ កែវ មេទ័ព ជើងទឹក លោក រំដោះ បាន វិញ ខេត្ត ខ្មែរ ពីរ រយ៉ង និង ចន្ទបូរី ដែល សៀម វាយ យក បាន ពី អតិតកាល។ លោក តាំង ទី បញ្ជាការ សេនាធិការ ក្នុង ខេត្ត រយ៉ង រង់ចាំ រាជបញ្ជា ថ្មី ពី ព្រះមហាក្សត្រ ដែល កំពុង បោះ ពន្លាជ័យ នៅ ខេត្ត មឿងបស្ចិម។

ក្រោយ ពី បាន ស៊ើប បានដឹង ច្បាស់ពិត ថា ឥឡូវ នេះ ប្រទេសសៀម ឈប់ មាន កើត កោលាហល ទៀតហើយ ព្រោះ ឃុន ពិរេន្រ្ទទេព, ឃុនព្រះឥន្ទទេព, ម៉ឺនរាជស្នេហា, លួងស៊ីយ៉ត នាំ គ្នា ងើប បះបោរ ទម្លាក់ ពញា វរវង្សា ពី អំណាច ហើយ ថែម ទាំង បាន ប្រហារ ជីវិត ជន ដណ្ដើមរាជ្យ នោះ ព្រម ទាំង ម្ដាយ ទៅទៀត។ ឥឡូវនេះ ចតុជនាភិបាល[2] បាន លើក ប្រធានរាជា ជា ព្រះវង្ស ៤ សោយរាជ្យ ទ្រង់ ព្រះនាម ព្រះមហាចក្រពត្រាធិរាជ។

ព្រះសេរីរាជា នោះ បី ជ្រាប ដឹងច្បាស់ ពី សភាពការណ៏ នេះ តែ ព្រះរាជាខ្មែរ ទ្រង់ នៅ តែ មាន ព្រះទ័យ លើក ទ័ព ទៅ វាយ រាជធានីសៀម តែ ជំនាន់ នោះ ទ័ពខ្មែរ គ្មាន

---

2 ចតុជនាភិបាល; ពួក អ្នកដឹកនាំ ទាំង បួន នាក់។

កាំភ្លើងធំ សោះ ឯចំណែក ខាង សៀមវិញ គេ មាន កាំភ្លើងធំ ច្រើន អាច បាញ់ ពី បន្ទាយ នាំ ឲ ទ័ពខ្មែរ ចូល ជិត ពុំ បាន។ បន្ទាប់ ពី សាកល្បង ច្រើនលើកគ្រា វាយ បន្ទាយ របស់សៀម តែ នៅ ឥត បែក ហើយ នាំ ឲ ស្លាប់ ពលខ្មែរ ជា ច្រើន។ ព្រះសេរីរាជា ក៏ សំរេចចិត្ត ដក ទ័ព ត្រឡប់ មកតាំង នៅ ខេត្ត បស្ចិម វិញសិន ហើយ ពេល ដក ទ័ព នោះ ទ័ពសៀម ឃើញ ហើយ តែ ពុំ ហ៊ាន លើក តាម ទេ។

និយាយ ពី នៅ ក្នុង នគរខ្មែរ វិញ នៅ ពេល ដែល ព្រះសេរីរាជា លើក ទ័ព ទៅ វាយ សៀម ព្រះរាជបុត្រ មតកក្សត្រ ព្រះនរាយណ៍រាជា ព្រះនាម ព្រះស្រីសុរិយោទ័យ ជា ក្មួយ ព្រះសេរីរាជា ទ្រង់ មាន បំណង ដណ្តើម រាជ្យ។ ទ្រង់ ទៅ បបួល រាស្ត្រ និង នាម៉ឺនសព្វមុខមន្ត្រី នៅ ត្រើយ ខាងកើត បាន ច្រើន សុខចិត្ត ចុះចូល ជួយ ទ្រង់ រួច កេណ្ឌទ័ព លើក ទៅ សង្កត់ ខាងត្រើយ កំពង់សៀម ស្ទឹងត្រង់ បារាយណ៍ ជើងព្រៃ និង ត្រើយ ខាងជើង បាន ជា ច្រើន។

ដឹង ដំណឹង នេះ ភ្លាម ព្រះធម្មរាជា បាន បញ្ជា ឲ មន្ត្រី ខាង ព្រះអង្គ ចេញ ទៅ កាន់កាប់ ជា បន្ទាន់ ខេត្ត ទាំងឡាយ នៅ កម្ពុជាក្រោម សព្វថ្ងៃ នេះ តាំង ពី ខេត្ត សំរោងទង រហូត ដល់ ខេត្ត ទឹកខ្មៅ រហូត ទល់នឹង សមុទ្រ។ ខាង កោះស្លាកែត រហូត ដល់ ពាមមីថ ព្រៃនគរ

លង់ហោ ផ្សារដែក។ ទ្រង់ តាំង ចៅហ្វាយ ស្រុក ថ្មី គ្រប់ ខេត្ត ត្បិត ចៅហ្វាយ ស្រុក ក្នុង ងារ គ្រប់ ខេត្ត ទាំង នោះ បាន ចូល ទៅ ក្នុង ក្បួនទ័ព ជាប់ ដង្ហែ ព្រះរាជា ទៅ ធ្វើ សង្គ្រាម នៅ ស្រុកសៀម អស់ ទៅ ហើយ។ លុះ ទ្រង់ ចាត់ ឲ រក្សា ខេត្ត មាំមួនហើយ ទ្រង់ បាន ចាត់ មន្ត្រី ឲ ទៅ ក្រាប ទូល ព្រះជេដ្ឋាធិរាជ ឲ ទ្រង់ ជ្រាប គ្រប់ ប្រការ។

ព្រះបាទសេរីរាជា ជ្រាបហើយ ទ្រង់ ត្រាស់ បង្គាប់ ឲ មេទ័ព ទាំងឡាយ កៀរ ឈ្លើយសៀម ហើយ ស្រូតរូត លើក ទ័ព ត្រឡប់ ចូល មក ក្រុង កម្ពុជាធិបតី វិញ តែ ទ្រង់ ទុក ទ័ព ចំនួន ៥.០០០នាក់ ដាក់ ក្រោម បញ្ជា ផ្ទាល់ ចៅហ្វាយ ខេត្ត បាត់ដំបង ឲ នៅ កាន់កាប់ ខេត្ត នាងរោង ដើម្បី រាំង ទ័ពសៀម។ ពេល ទ្រង់ យាង មក ដល់ ខេត្តពោធិសាត ទ្រង់ ជួបប្រទះ សារហារី ព្រះធម្មរាជា ជា អនុជ នាំ បន្ទូល ចូល ទៅ ថ្វាយ ទ្រង់ តាម សារសម្ងាត់ មាន សេចក្តី ថា៖

*សូម អញ្ជើញ ព្រះករុណា ពិសេស លើក ទ័ព ឆ្លង ត្រើយ កំពង់សៀម ហើយ វាយ ប្រសប់ ខ្ទប់ ពី ខាង ជើង ទ័ព ក្អួយ ស្រីសុរិយោទ័យ តែ ម្តង គង់ មាន ជ័យជំនះ ជា មិន ខាន មិន ចាំបាច់ ព្រះករុណា វិល ត្រឡប់ ចូល ក្រុង កម្ពុជាធិបតី សិន នោះឡើយ នាំ ឲ ខាត ពេលវេលា ព្រោះ ដំបន់ ខាងត្បូង និង ខាងលិច ថិត នៅ ក្រោម ការ*

*ត្រួតត្រា មាំមួន របស់ ទ័ព ទូលបង្គំ កុំ ឲ ព្រះករុណា ព្រួយ ព្រះរាជហឫទ័យ អ្វី នោះឡើយ។*

ព្រះសេរីរាជា ទ្រង់ ពេញ ព្រះទ័យនឹង យុទ្ធសាស្ត្រ នេះ ណាស់ ទ្រង់ លើក ទ័ព ជា ប្រយ៉ាប់ ទៅ វាយ ទ័ព ព្រះស្រីសុរិយោទ័យ តែ ម្តង ទទួល ជ័យជំនះ ដូច បាន គ្រោង ទុក មែន គឺ វាយ យក ស្រុក ត្រើយ ខាងជើង បាន វិញ ទាំងអស់។ ទទួលបាន ជ័យជំនះ រួចស្រេច អស់ហើយ ព្រះសេរីរាជា ទ្រង់ បាន បោះ ពន្លាជ័យ នៅ ស្រុកឆ្លូង មុន នឹង វឹល ត្រឡប់ ចូល រាជធានី តែ ពេល នោះ ព្រះស្រីសុរិយាទ័យ ទ្រង់ វាយលុក តបវិញ បែក បន្ទាយ ជា ច្រើន របស់ ព្រះអង្គ នោះ បី ទ្រង់ សាកល្បង វាយតបវិញ ជា ច្រើន គ្រា តែ នៅ តែ បរាជ័យ ដូច្នេះ ព្រះអង្គ ក៏ សំរេច ព្រះទ័យ នាំ ទ័ព ឆ្លង ទន្លេ មក ត្រើយ ខាងលិច វិញ។ ពេល ដក ទ័ព នោះ ពល ទាហាន ដែល មាន កំណើត នៅ ត្រើយ ខាងកើត នាំ គ្នា រត់ ចោល ជួរទ័ព ព្រោះ មិន ចង់ ទៅ ចោល គ្រួរសារខ្លួន។ ការលហបង់ នេះ នាំ ឲ ចំនួន កងទ័ព ព្រះរាជា ចុះជា ច្រើន បង្កើត ជា ការពិបាកនឹង បន្ត ធ្វើ សឹក បានទៀត ទ្រង់ ក៏ សំរេច ព្រះទ័យ ដកថយ ទ័ពហ្លួង មក បោះ ពន្លា ជា បណ្តោះ អាសន្ន ក្នុង បន្ទាយ ខេត្ត អម្រាគគិរិន្ទបូណ៌ តែ ទ្រង់ ទុកទ័ព ឲ នៅ រក្សា ខេត្ត កំពង់សៀម ជើងព្រៃ ស្ទឹងត្រង់ ដែល ជា ខេត្ត នៅ ត្រើយ ខាងជើង។

ត្រឡប់ មក និយាយ ពី ព្រះធម្មរាជា វិញ ដឹង ដំណឹង ថា ព្រះជេដ្ឋា ជួប ការពិបាក ក្នុង ការបន្ត ធ្វើ សឹក នឹង ទ័ព ព្រះស្រីសុរិយោទ័យ ទ្រង់ កើត មាន ចិន្តា រៀប ដើងព្រួល ទប់នឹង កំហឹង ព្រះជេដ្ឋា តាម ការញុះញង់ ជា ច្រើន លើក មកហើយ ពី បរវារ ព្រះជេដ្ឋា មក លើ ទ្រង់ ដូច្នេះ ទ្រង់ គិត ថា ត្រូវ តែ ទ្រង់ ពឹង ខ្លួនទ្រង់ ដើម្បី សុវត្ថិភាពទ្រង់ ជា បឋម ដោយ យក យុទ្ធសាស្ត្រ « ការការពារ ខ្លួន ដ៏ ល្អ មួយ គឺ ត្រូវ វាយ ប្រហារ មុន »។ គិត ឃើញ បែប នេះ រួច ហើយ ទ្រង់ បញ្ជា ឲ មន្ត្រី រាជទូត នាំ គ្រួសារ មាន ព្រះ ទេពី នារី ស្រី ព្រះស្នំ និង ព្រះរាជទ្រព្យ ព្រះបាទសេរីរាជា ទៅ ថ្វាយ ព្រះជេដ្ឋា ជា មួយគ្នា នោះ ដែរ ព្រះធម្មរាជា ទ្រង់ ធ្វើ ចុតហ្មាយ ថ្វាយ ព្រះជេដ្ឋា ថា៖

*សូម ព្រះករុណា កុំវិល ត្រឡប់ ចូល ក្រុង ចតុម្មុខ វិញ ព្រោះ នាំ ឲ ខូច ការណ៏សឹក ដោយ ហេតុ ទុក ឲ ទ័ព នៅ ក្រោម ការត្រួតត្រា ព្រះជេដ្ឋា គ្មាន ការគាំទ្រ ពី ទ័ពហ្លួង និង ជា បង្អែក យុទ្ធសាស្ត្រ ដើម្បី ទប់ទល់នឹង ការវាយប្រហារ របស់ ទ័ព ព្រះភាគិនេយ្យា (ក្មួយ) ស្រីសុរិយោទ័យ។*

ជាមួយគ្នា នោះ ដែរ ព្រះធម្មរាជា បាន បញ្ជា ឲ មន្ត្រី ព្រះ អង្គ នាំ ទ័ពធំ មួយ ទៅ បោះ នៅ ស្រុក ឧដុង្គ ក៏ ចាប់ ផ្តើ ម ធ្វើ ប្រតិបត្តិការសឹក វាយ រាំង ទ័ព ព្រះស្រីសុរិយាទ័យ នៅ ល្វាឯម និង ទិស ខាងត្បូង ហើយ រៀបចំ ធ្វើ ខ្សែ

ក្រវាត់ ការពារ ទ័ព ព្រះរាជា នៅ បែក ខាងជើង និង តាំង ហាត់ សេនាទាហាន ប្រមូល ស្បៀងអាហារ នៅ ក្នុង ព្រះនគរ ដើម្បី ការពារ ជា យថាហេតុ ពី ការវាយប្រហារ របស់ ទ័ព ព្រះជេដ្ឋា ក្ដី ឬ ព្រះភាគិនេយ្យ ក្ដី ចូល ក្រុង ចតុម្មុខ។ ឯចំណែ ព្រះបាទសេរីរាជា ក្រោយ ពី បាន អាន សេចក្ដី ក្នុង ចុតហ្មាយ សព្វ គ្រប់ អស់ហើយ យល់ដឹង ភ្លាម ពី បំណងខ្មៅ របស់ ព្រះអនុជ ចង់ ញែក ព្រះអង្គ ពី រាជបល្ល័ង្គ ក្រុង ចតុម្មុខ។ ទ្រង់ ខ្វាល់ណាស់ មាន បំណង លើកទ័ព ទៅ វាយ ព្រះធម្មរាជា ភ្លាម តែ អស់មន្ត្រី របស់ ព្រះអង្គ អន្ទង ព្រះអង្គ កុំ ឲ បង្កើត សមរភូមិ ទី២ ព្រោះ ខ្លាច ព្រះធម្មរាជា និង ព្រះស្រីសុរិយោទ័យ ចូល គំនិតគ្នា មក វាយទនឹង ព្រះអង្គ។

ក្រោយ ពី បាន ទទួល ជ័យជំនះ ច្រើនគ្រា លើ ទ័ព ព្រះបាទសេរីរាជា ព្រះស្រីសុរិយោទ័យ ត្រូវ បាន នាយក កងទ័ព និង អស់ មុខមន្ត្រី របស់ ទ្រង់ អញ្ជើញ ព្រះអង្គ ឲ ឡើង សោយរាជសម្បត្តិ ផែនដី ក្នុង ព្រះជន្មាយុ ២៦ ព្រះ វស្សា ឯចំណែក ព្រះធម្មរាជា ទ្រង់ ពុំ ព្រម ទទួល តាម សេ ចក្ដី ស្នើ សុំ ពី អស់មន្ត្រី ព្រះអង្គ ឲ ទ្រង់ ឡើង សោយរាជ សម្បត្តិ ផែនដី នៅ ក្រោម ការត្រួតត្រា របស់ ព្រះអង្គ ដូច ព្រះភាគិនេយ្យ នោះទេ; ទ្រង់ គ្រាន់ តែតាំងខ្លួន ជា អ្នក រក្សា ផែនដី ឋិត ក្រោម ការត្រួតត្រា ទ័ព របស់ ព្រះអង្គ

តែប៉ុណ្ណោះ។ តែ ក្រោយមក ក្នុង ឆ្នាំ ១៤៧៨ ព្រះអង្គ ក៏ សុខចិត្ត តាម ការក្ជួន ជា ច្រើនគ្រា ពីសំណាក់ នាម៉ឺន សព្វមុខមន្ត្រី របស់ ព្រះអង្គ ឲ ទ្រង់ ឡើង សោយរាជ សម្បត្តិ ផែនដី ក្នុង ជន្មាយុ ២៦ វស្សា។ ដូច្នេះ ស្រុកខ្មែរ នៅ ជំនាន់នោះ មាន បែង ចែក ជា បី ផែនដី៖

## ផែនដី ព្រះបាទសេរីរាជា៖

ផែនដីព្រះបាទសេរីរាជា មាន បណ្ដាខេត្ត ចំណុះ ព្រះអង្គ ឋិត ក្នុង ផែនដី ឧត្តរទិស គឺ តាំង ពី ខេត្ត លង្វែក រលា ប្អៀ អម្រាគគិរិបូណ៌ ក្រគរ គ្រង ពោធិសាត់ បាត់ដំបង ឫស្សីសាញ តាមសីមា មង្គលបូរី រយ៉ង សុរិន្ទ សិង្ការ កំពង់ សៀម ស្ទឹងត្រែង ដើងព្រៃ គោកសេះ អន្ទង់រាជ ព្រាំទេព ព្រៃក្ដី ស្ទោង ជីក្រែង រលួស សៀមរាប មូលព្រៃ ជាំក្សាន្ត ត្នោត ទឹកជោរ រៀង ទៅទល់នឹង ដែន សៀម។

## ផែនដី ព្រះធម្មរាជា៖

ផែនដី ព្រះធម្មរាជា មាន បណ្ដាខេត្ត ចំណុះ ព្រះអង្គ គឺ ប ណ្ដា ខេត្ត ក្រោយ ខាងលិច ដែល មិន នៅ ក្រោម ចំណុះ ព្រះជេដ្ឋា ទាំងអស់ ថែម ទាំង ខេត្ត តាំង ពី សំរោងទង បាទី លើកដែក ទ្រាំង បន្ទាយមាស ថ្ពង បាសាក់ បារៀ ពាម កៅស្លាកែត (ស្រុក លើកដែកសព្វថ្ងៃ) កំពត កំពង់

សោម ព្រះត្រពាំង ក្រមួនស ដូនណៃ រៀង ទៅទល់នឹង សមុទ្រ។

## ផែនដី ព្រះស្រីសុរិយោទ័យ៖

ផែនដី ព្រះស្រីសុរិយោទ័យ ក្នុង ឆ្នាំ ១៤៧១ មាន ខេត្តចំណុះ ដូច តទៅ៖ តាំងពី ខេត្ត សៀមបូក សម្បុកសម្បូណ៌ ក្រចេះ ឆ្លូង ត្បូង បាសាន ទទឹងថ្ងៃ ព្រៃវែង បាភ្នំ រំដួល ស្វាយទាប រោងដំរី ព្រៃនគរ លងហោ ជើងបាដែង រៀង ទៅទល់នឹង នគរ ចាម។

ក្នុង រាជវិវាទ ជា ត្រីកោណ នេះ មាន រយះពេល ដប់ ឆ្នាំ នាំ ឲ រហ័ពល រាស្ត្រ ស្លុយ ស្លាប់ ជា ច្រើន នាក់ តែ គ្មាន ផែនដី ណា មួយ មាន ប្រៀប ជាង គេ នោះឡើយ ក៏ នាំ គ្នា ផ្អាក សង្គ្រាម នៅ ស្ងៀម។ ស្តេច ទាំង បី ព្រះអង្គ ក៏ សំរេចចិត្ត នៅ រក្សា ផែនដី របស់ទ្រង់ រៀងខ្លួន រង់ចាំ ឪកាសល្អ ដើម្បី បន្ត សង្គ្រាម ស៊ីវិល តែ យុទ្ធវិស្រម (trêve) នេះ ត្រូវ បាន ព្រះសេរីរាជា បញ្ឈប់ មុនគេ។ ទ្រង់ បាន លើកទ័ព វាយ សំរុក ចូល ក្នុង ផែនដី ព្រះសុរិយោទ័យ ជា ច្រើនគ្រា តែ ពុំ ទាន់ ចាញ់ ឈ្នះ ម្ខាងៗ ឡើយ។ សង្គ្រាម កើតមាន ឡើង ជា ថ្មី នោះ នាំ ឲ អស់ អាណាប្រជានុរាស្ត្រ វិនាស ដោយ ជម្ងឺ ជា ច្រើន។ ប្រទេស កើត កោលាហល ខ្លាំងណាស់ ចោរខ្មួញ ក៏ កម្រើក ថ្លើម ធំ ប្លន់ កាប់ចាក់ សម្លាប់ ប្រជារាស្ត្រ គ្រប់ ស្រុក គ្រប់ ដំបន់។

ក្នុង ឆ្នាំ ១៨៨៥ ព្រះធម្មរាជា មើល ឃើញ សភាពការណ៍ បែប នេះ ទ្រង់ មាន ព្រះរាជហឫទ័យ អាណិត រាស្ត្រ ទើប ទ្រង់ តែង សុភអក្សរ ៤ ព្រះរាជតេជទូត ចុះ ទូក យក ចុតហ្មាយ នេះ ទៅ ថ្វាយ ព្រះចៅសៀម នៅ ក្រុង ទេពបុរី ក្នុង គោលដៅ សូម អញ្ជើញ ព្រះចៅចក្រពត្តិ ៤ លើក ពួហៈ កងទ័ព ទៅ ជួយ ប្រាបប្រាម សង្គ្រាម រវាង ព្រះសេរីរាជា នឹង ព្រះសុរិយោទ័យ ដើម្បី សេចក្តីសុខ ដល់ បណ្តារាស្ត្រ។ ក្នុង ចុតហ្មាយ នោះ ព្រះធម្មរាជា មាន ការស្នើ សូម ដល់ ព្រះចៅសៀម សូម ៤ ទុក ស្រុកខ្មែរ និង សៀម ជានគរ តែមួយ បើ ព្រះនគរ ខាង ណា កើត សឹក សង្គ្រាម ព្រះនគរ ម្ខាង ទៀត នឹង លើក ទ័ព ទៅ ជួយ គ្នា ទៅវិញទៅមក ទុក ព្រះ មហាក្សត្រ ទាំង ពីរ ជា ព្រះរៀម ព្រះអនុជ នឹងគ្នា។

លុះ អាល័ក្ស សូត្រ សេចក្តី ព្រះរាជសារ ចប់ហើយ ព្រះចៅចក្រពត្តិ ទ្រង់ ព្រះអំណរណាស់ ស្តេច ត្រាស់ សួរ ថា - *ព្រះរៀម នេះឬ ដែល មាន មាតា របស់ ព្រះអង្គ ជាតិសៀមសុទ្ធ មាន នាម ស៊ី សាងាម ?* ព្រះរាជតេជទូត ក្រាប ទូលថា - *សូម ទ្រង់ ព្រះមេត្តាប្រោស សេចក្តីនេះ ដូច ព្រះរាជតម្រាស់ហើយ។*

ព្រះចៅចក្រពត្តិ បាន ទ្រង់ ជ្រាបជៀង ជាក់ ថា ព្រះធម្មរាជា ជា វង្សសៀម ព្រះអង្គ យល់ ព្រម តាម ការស្នើ សូម

នោះ ព្រោះ ជា ឱកាស មួយ ដ៏ ល្អ សំរាប់ សងសឹក ព្រះសេរីរាជា កាល ទ្រង់ មក វាយ ប្រទេសសៀម។ ទើប ទ្រង់ ត្រាស់ បង្គាប់ មេទ័ព ជើងទឹក យុំ ពល បី ពាន់នាក់ លើក ចូល មក ក្រុង កម្ពុជាធិបតី តាម ផ្លូវ កំពត ពាម បន្ទាយមាស ឯចំណែក ព្រះអង្គ លើក ទ័ពហ្លួង ជា ទ័ពធំ ចូល ស្រុកខ្មែរ តាម ផ្លូវ ខេត្ត បាត់ដំបង ពោធិសាត់ ក្រង ខ្លុង ចូល ដល់ ខែត្រ អម្រាគគិរិន្តបូណ៌ ជួបនឹង សម្តេច ធម្មរាជា ដែល យាង មក ចាំ ព្រះអង្គ នៅ ទី នោះ តាម ការណាត់គ្នា។ ស្តេច ទាំង ពីរ ទុក ព្រះទ័យ សោមនស្ស គ្មាន រង្គាល ទាំងសងខាង ស្តេចខ្មែរ ត្រាស់ ហៅ ព្រះចៅ សៀម ថា អនុជ ខាង ស្តេចសៀម ត្រាស់ ហៅ ស្តេចខ្មែរ ថា ព្រះរៀម ហើយ នាំ គ្នា ទ្រង់ ព្រះតម្រិះ កិច្ចការ សង្គ្រាម នៅ ក្នុង បរិយការណ៍ ជា មេត្រីភាព យ៉ាង ធំ សមនឹង ឋានះ ជា បងប្អូន ជា ទីស្រឡាញ់។ បន្ទាប់មក ស្តេច ទាំង ពីរ ព្រះ អង្គ ក៏ លើក ទ័ព ខ្មែរ-សៀម ឆ្លង ទៅ ទិស ខាងកើត ចោម បន្ទាយ ព្រះសេរីរាជា ភ្លាម នៅ ខេត្ត កំពង់សៀម។

ព្រះសេរីរាជា លុះ ទ្រង់ ស្តេច បាន ជ្រាប ថា ព្រះអនុជ ឲ ទូត ទៅ អន្ទង ទ័ពសៀម មក ច្បាំងនឹង ព្រះអង្គ ទ្រង់ មាន ព្រះ តម្រាស់ ប្រឹក្សានឹង សេនាបតី មន្ត្រី ជា មេ កង ទ័ព ធំតូច ដើម្បី រក មធ្យាបាយ ទប់ទល់នឹង វិការ (ការ ប្រែប្រួល) នៃ សភាពការណ៍ សឹក។ ខណៈ នោះ មាន

យោបល់ ពីរ ខុសគ្នា ខាង មន្ត្រី ស៊ីវិល តាម រយៈ សម្ដេចចៅហ្វាទឡ្ហ យល់ ឃើញ ថា ទ័ព ព្រះនគរ ពុំ អាច ទប់ទល់នឹង ទ័ព សម្ពន្ធមិត្ត សៀម-ខ្មែរ នោះ បាន ទេ ដ្បិត ទ័ពគេ នៅ ថ្មីថ្មោង ស្បៀងអាហារ អាវុធ យុទ្ធភ័ណ្ឌគេ ក៏ បរិបូណ៌ តែ ម្ខាង មេទ័ព យល់ ឃើញ ផ្ទុយ ពី ខាង ស៊ីវិល នាំ គ្នាថ្វាយ យោបល់ ដល់ ព្រះចៅខ្លួន ថា ដ្បិត សៀម វា ធ្លាប់ចាញ់ ថ្វីដៃ ទ័ពយើង ឯចំណែក ទ័ពខ្មែរ ខាងលិច (ទ័ពព្រះធម្មរាជា) នៅ ថ្មី តែ គ្មាន ការពិសោធន៍ ក្នុង សង្គ្រាមព្រោះ តាំង ពី មាន វិវាទ ក្នុង ព្រះនគរ មក ពុំ សូវ ចូលច្បាំងសោះ គិត តែការពារ ផែនដី តែប៉ុណ្ណោះ ; ទុព្វលភាពរបស់សត្រូវ នេះ ជា ទ្រព្យ សំរាប់ ទ័ពយើង ទៅ វិញទេ ទោះបី យើង មាន ការនឿយហត់ ក្នុង សង្គ្រាម យ៉ាង ណា ក៏ដោយ អាហារ សស្ត្រាវុធ ក៏ ស្ដួចស្ដើង ពិតមែន តែ យើងមាន ប្រៀប តាម កម្លាំងចិត្ត និង ការពិសោធន៍ ក្នុង សង្គ្រាម អាច នាំ ឲ យើង មាន ជ័យជំនះ លើ ទ័ព សម្ពន្ធមិត្តសៀម-ខ្មែរ ជា ពុំ ខាន។

ក្រោយ ពី បាន ស្ដាប់ យោបល់ សព្វគ្រប់ អស់ មុខមន្ត្រី រួចហើយ ព្រះសេរីរាជា ទ្រង់ ស្វែងយល់ ថា ខាង មន្ត្រី ស៊ីវិលយល់ សមហេតុផល ជាង ខាង យោធា ទ្រង់ សំដែង ការអរ ណាស់ ពី សេចក្ដីក្លាហាន និង ចិត្ត ឈឺឆ្អាល ពី សំណាក់បណ្ដា មេទ័ព ធំតូច ពី ទឹកចិត្ត ជួយ យក អាសា ព្រះអង្គ

តែ ទ្រង់ សំរេច ចិត្ត ឈរ លើ ការពិត ជាង សេចក្តី ស្រើប ចិត្ត គឺ យក ការចរចា សុំ ចុះចូល ជា មួយ ទ័ព សម្ពន្ធមិត្ត សៀម-ខ្មែរ ព្រោះ នឹង ធ្វើ សង្គ្រាម ទល់នឹងគេ គឺ ពិត ចាញ់គេ ដូច្នេះ ជា វញ្ឆកម្ម (អំពើឥតផល) នាំ រហែពល និង រាស្ត្រ ស្លាប់ គ្មាន ប្រយោជន៍។ មាន ព្រះបន្ទូល រួច ព្រះសេរីរាជា ស្តេច ត្រាស់ ប្រើ រាជតេជទូត ៤ ទៅ ទូល ព្រះធម្មរាជា ថា ព្រះអង្គនឹង បញ្ឈប់ ធ្វើ សង្គ្រាម ភ្លាម ជា មួយ នឹង ទ័ព ព្រះស្រីសុរិយោទ័យ។ ព្រះធម្មរាជា និង ព្រះចៅចក្រពត្តិ កាល ទ្រង់ ជ្រាបហើយ មាន ព្រះអំណរណាស់ ស្តេច ទាំង ពីរ ព្រះអង្គ ត្រាស់ បង្គាប់ ៤ រាជទូត នោះ នាំ ចម្លើយ ថ្វាយតប ព្រះសេរីរាជា ថា សូម អញ្ជើញ ព្រះរាជា ៤ ព្រះអង្គ យាង មក ស្រុក រោងទង ក្នុង ខេត្ត កំពង់ចាម មក ជួប ជុំគ្នា ដើម្បី ធ្វើ បុណ្យ អបអរសាទរ នៃ សន្តិភាព នេះ។

ខណៈ នោះ ព្រះចៅចក្រពត្តិ ទទួល ព្រះសេរីរាជា ក្នុង មេត្រីភាព ទ្រង់ ក្រាប ទូល ស្តេចខ្មែរ ថាៈ

*ខ្ញុំ ជា អនុជ លើក ទ័ព មក នេះ ព្រោះ ព្រះរៀម និង ព្រះភាគិនេយ្យា ទ្រង់ ធ្វើ សង្គ្រាម យូរ ឆ្នាំ មកហើយ ពុំ សម្រេច ដូច្នេះ សូម កុំ ៤ ទ្រង់ តូច ព្រះទ័យ ឡើយ សូម តាំង ព្រះទ័យ ជួយ ព្រះពុទ្ធសាសនា បំបាត់ ទុក្ខ ប្រជារាស្ត្រ ៤ បាន នៅ សុខក្សេមក្សាន្ត; ខ្ញុំ សុំ អញ្ជើញ ស្តេច ទៅ គង់*

*ក្រុង ទេពបុរី ជាមួយគ្នា ឯចំណែក ពញាអុង ជា បុត្រ ព្រះអង្គ ខ្ញុំ សុំ ជា បុត្រធម៌ នឹង ទំនុក បម្រុង ឲ្យ ដូច ជា រាជបុត្រ បង្កើត របស់ ទូលបង្គំ ឯ មុខមន្ត្រី បណ្ដា ជា ខ្ញុំ នឹងចង់ ទៅ តាម ប៉ុន្មាន ក៏ ទៅ តាម ស្ម័គ្រចិត្ត ចុះ។*

ស្ដេចសៀម ត្រាស់ ចប់ សព្វគ្រប់ហើយ ទ្រង់ យាង ចូលពន្លាជ័យ តែ ព្រះអង្គឯង ទុក ឲ្យ នាយកងទ័ពសៀម ដែលបាន ទទួល ណាត់ កិច្ចការ ទាហាន នោះ ឃុំ សម្ដេច សេរីរាជា ពញាអុង និង ខ្ញុំ រាជការ ទុកសិន។ បន្ទាប់មក ព្រះចៅចក្រពត្តិ ឲ្យ រាជទូត ទៅ អញ្ជើញ ព្រះស្រីសុរិយោទ័យ ពីត្រើយ ខាងកើត ដើម្បី ចរចា រៀបចំ ឲ្យ ព្រះនគរ ឲ្យ បានសុខសាន្ត ឡើងវិញ។

ព្រះស្រីសុរិយោទ័យ ទ្រង់ ជ្រាប ថា សៀម ចាប់ ព្រះបិតុលា (ឪពុកមា) ទ្រង់ មាន អំណរ ណាស់ ដោយ មាន វិចិន្ដា ថា ព្រះចៅសៀម នឹង ឲ្យ ព្រះអង្គ ឡើង សោយរាជសម្បត្តិ ជាពុំ ខាន ព្រោះ ព្រះជម្មរាជា ជា មា របស់ ព្រះអង្គ ពិតមែនតែ ព្រះជន្មវស្សា តិច ជាង ទេ បើ មិន ដូច្នេះ ព្រះចៅ គង់នឹង ពិភ័ក្តិ (ការចែក) ផែនដី ជា ពីរ ស្មើគ្នា ពុំ ខាន។ លុះទ្រង់ ព្រះចិន្ដា ដូច្នេះហើយ ទ្រង់ ក៏ សំរេចចិត្ត យាង ទៅជួបនឹង ព្រះចៅចក្រពត្តិ។ ខណៈ នោះ ស្ដេចសៀម ទ្រង់ត្រាស់នឹង ព្រះស្រីសុរិយោទ័យ ថា៖

*សម្តេច ព្រះសេរីរាជា និង ព្រះអង្គ ជា គូ សង្គ្រាម នឹងគ្នា កន្លងនេះ បើ យើង យក តែ មួយ អង្គ ទៅ ក្រុងទេពបុរី ដូច ជា អយុត្តិធម៌ ណាស់ ហេតុ ដូច្នេះ សូម អញ្ជើញ ក្លួយ ទៅ ក្រុងទេពបុរី ជា មួយ ព្រះបិតុលាចុះ។*

ព្រះចៅចក្រពត្តិ ត្រាស់ ចប់ ប៉ុណ្ណោះហើយ ក៏ ឲ ទាហាន អញ្ជើញ ព្រះស្រីសុរិយោទ័យ ចូល ក្នុងបន្ទាយ។ កងទ័ព ទាំងឡាយ ដែល ហែហម ព្រះស្រីសុរិយោទ័យ នឹង ចូល ទៅ តាមផង ពុំ បាន ព្រោះ ទាហានសៀម ឃាត់ មិន ឲ ចូល ដូច្នេះ ក៏ នាំ គ្នា ថយ មក ចាំ ស្តាប់ ការណ៏ នៅ ខាង ក្រៅ លុះ បាន ដឹង ថា សៀម ឃុំ ស្តេចខ្លួន នឹង យក ទៅ ស្រុក សៀម ក៏ ទាល់ គំនិត ភិតភ័យ ហើយ នាំ គ្នា រត់ ត្រឡប់ ទៅ ស្រុក វិញអស់។

សំរេច អស់ ដល់ គោលបំណង ដែល បាន រៀបចំទុក ជា មុន នេះហើយ ព្រះចៅចក្រពត្តិ ស្តេច ក៏ លើក ទ័ព នាំ ក្សត្រខ្មែរ ទាំង ពីរ ព្រះអង្គ និង គ្រួសារសៀម ដែល ព្រះ សេរីរាជា បាន កៀរ ពី អតីតកាល យាង វឹល ត្រឡប់ ទៅ ស្រុកសៀម វិញ។ ព្រះធម្មរាជា ទ្រង់ យាង ជូន ដំណើរ ព្រះ ចៅសៀម រហូត ដល់ ខេត្ត លង្វែក រួចហើយ ស្តេច ទាំង ពីរ ព្រះអង្គ ក៏ ថ្វាយ បង្គំ លា គ្នា នៅ ត្រង់នោះ។

ក្នុង ដំណើរ វឹលត្រឡប់ ទៅ ស្រុកសៀម នោះ ព្រះសេរីរាជា ព្រះអង្គ តូច ព្រះទ័យណាស់ និង មាន លជ្ជីភាព (សេចក្តី

ខ្មាស់) ចំពោះ ព្រះអង្គខ្លួនឯង ព្រោះ ចាញ់ ល្បិច ដោយ វញ្ចនការ (ការបោកប្រាស់)។ ទ្រង់ ពុំ សោយ សោះ អស់ ព្រះកាយពល ទាល់ តែ ទ្រង់ ព្រះអាពាធ (ឈឺ) ជា ទម្ងន់ ក៏ ទទួល សុគត ទៅ; ឯចំណែក ព្រះស្រីសុរិយោទ័យ ក្រោយពី ទ្រង់ យាង ដល់ ក្រុងទេពបុរី បាន ១៥ ថ្ងៃ មាន អាពាធ ជា ទម្ងន់ ហើយ ទ្រង់ សុគត ទៅ។ ព្រះចៅចក្រពត្តិ ចេញ រាជបញ្ញត្តិ តាំង ជា ផ្លូវការ ពញា អុង ជា ព្រះរាជបុត្រធម៌ របស់ ព្រះអង្គ ទ្រង់ ថ្វាយ ព្រះនាម ព្រះសុទ្ធានរាជា ទុក ជា បុត្រច្បង ទ្រង់ ប្រោស ព្រះទាន ព្រះរាជបុត្រីបង្កើត ១ ជា ព្រះជាយា និង ព្រះស្នំ ក្រមការ ទាំងពួងហើយ ឲ យាង ទៅ គ្រង ស្រុក សុវណ្ណខាកលោក។

ព្រះបាទ សម្ដេច ស្រីធម្មរាជា បាន ក្លាយ ជា ព្រះចៅ ក្រុង កម្ពុជា តែមួយ។ ទ្រង់ ប្រោស ព្រះរាជទាន រង្វាន់ ដល់ អស់ មុខមន្ត្រី ឲ ឡើង យសសក្តិ សម តាម ស្នាដៃ រៀងៗខ្លួន និង ទ្រង់ លើកលែង យក ពន្ធការបុគ្គល និង ពន្ធ ព្រះរាជ ធានី ៣ ឆ្នាំ ដើម្បី ជួយ សំរាល បន្ទុក ជីវភាព អាណាប្រជា នុរាស្ត្រ។ ព្រះអង្គ បាន បន្ត សោយរាជសម្បត្តិ ដោយ កិត្តិគុណ អស់រយះ ពេល ១៩ ឆ្នាំ ទ្រង់ សោយព្រះទិវង្គត ក្នុង ឆ្នាំ ១៥០៤ ក្នុង ព្រះជន្មាយុ ៦៤ វស្សា ដោយ ព្រះរោគ។

# អត្ថាធិប្បាយ

សំណួរ សួរ ថា តើ ព្រះធម្មរាជា ជា ស្តេច សង្គ្រោះជាតិ ឬ ជា ស្តេច ក្បត់ជាតិ ?

យើង ឃើញ ថា ចាប់ ពី ឆ្នាំ ព្រះបាទសេរីរាជា (១៤៣៣-១៤៨៥) លើក ទ័ព ទៅ ច្បាំង នឹង នគរសៀម ក្នុង ឆ្នាំ ១៤៥៣ មក ដល់ ពេល ព្រះអង្គ ត្រូវ បាទ ស្តេចសៀម ចាប់ ឃុំ ព្រះអង្គ បាន ក្នុង កំឡុង ឆ្នាំ ១៤៨៥ ហើយ នាំ យក ទៅ ស្រុកសៀម ជាមួយនឹង ព្រះស្រីសុរិយោទ័យ ជា ក្មួយ និង ជា សត្រូវរាជ្យ ស្រុកខ្មែរ ឋិត នៅ ក្នុង ស្ថានភាព ជា ស្រុក មាន ចម្បាំង អស់រយៈពេល ដ៏យូរមួយ គឺ ៣២ ឆ្នាំ។ ក្នុង រយៈពេល នោះ បើ យើង គិត ពី ឆ្នាំ ដែល ព្រះស្រីសុរិយោទ័យ បាន ធ្វើ អត្ថប្រកាស ក្នុង ឆ្នាំ ១៤៧១ ឡើង សោយរាជសម្បត្តិ ជាន់ លើ រាជ្យ ព្រះបិតុលា មាន សង្គ្រាមស៊ីវិល ក្នុង នគរ ជាង ១៤ ឆ្នាំ។ ក្នុង រយៈពេល ជាង បី ទស្សវត្សរ៍ នោះ ប្រជារាស្ត្រ បាន ជួប ប្រទះនឹង ទុក្ខ វេទនា ក្រៃលែង។ ឈរ លើ បទដ្ឋាន នោះឯង ព្រះធម្មរាជា ទ្រង់ បាន ស្នើ សុំ ស្តេចសៀម ៤ យាង មក ធ្វើ អន្តរាគមន៍ យោធា ក្នុង ស្រុកខ្មែរ ដើម្បី រក សន្តិភាព ជូន ដល់ ប្រជារាស្ត្រខ្មែរ។ ទង្វើ របស់ ព្រះធម្មរាជា នោះ តើ យើង អាច ទុក ជា អំពើ វិជ្ជមាន ឬ អវិជ្ជ សំរាប់ ជាតិខ្មែរ ?


សរសេរ ដោយ ឧប សៅ សង្ហា
ថ្ងៃទី១ មីនា ២០១៧

សារជាតិ នៃ អំពើ នោះ គឺ វា ស្ថិត នៅ លើ អត្ថរស់ នៃ « សន្តិភាព » ដែល ព្រះធម្មរាជា ទ្រង់ យក កម្លាំង បរទេស មក ធ្វើ ជា គ្រឿងផ្សំ សំរាប់ ដាក់ ជូន ភាគីខ្មែរ ជា យុទ្ធការី នៃ វិវាទ ៤ បរិភោគ ដើម្បី បន្សាប ចំបាំង ស៊ីវិល ពង្រេចពង្រិលជាតិ ក្នុង រយះពេល ៥ យូរ មួយ។

## ធាតុ នៃ សង្គ្រាម

មុន នឹង ពិចារណា អំពី អត្ថរស់ នៃ សន្តិភាព គួរ យើង លើក ជា អាទិ យក ធាតុ នៃ សង្គ្រាម ដែល មាន កើត ឡើង នោះ មក ពិចារណា។ ជា ការ ជាក់ស្តែង ណាស់ ធាតុ សង្គ្រាម នោះ ជា សង្គ្រាម កើត ពី វិវាទ ក្នុង រាជវង្ស នាំ គ្នា ធ្វើ សង្គ្រាម នឹងគ្នា ដើម្បី ដណ្តើម និង រក្សា រាជបល្ល័ង្ក។ ដូច្នេះ សង្គ្រាម នោះ មាន ធាតុ ជា សង្គ្រាម បំផ្លាញ ជាតិ បំបែក ឯកភាពជាតិ និង បង្កើត ទុក្ខ ដល់ ប្រជារាស្ត្រខ្មែរ។

សង្គ្រាម នោះ វា បង្ហាញ នូវ ភាព បរាជ័យ នៃ សំវាទ ក្នុង រាជវង្ស និង អស្ថិរភាព នៃ រាជសក្តិ (អំណាចស្តេច) ដែល ច្រើន មាន កើតឡើង ពី អវត្តមាន នៃ ច្បាប់ ស្នងរាជ្យ សម្បត្តិ ទៀងទាត់ ដែល ជា មូលហេតុ នៃ វិវាទ រវាង អភិមានិក នៃ រាជបល្ល័ង្ក។

## នរណា ជា អ្នក ខុស ?

## កំហុស ព្រះមហាក្សត្រ សេរីរាជា ?

ព្រះមហាក្សត្រ សេរីរាជា ព្រះអង្គ ជា ស្តេច ឡើង សោយ រាជ្យ តាម ផ្លូវ នីត្យានុកូល ដូច្នេះ ព្រះអង្គ ធ្វើ សង្គ្រាម បង្ក្រាប ព្រះស្រីសុរិយោទ័យ ជា ក្មួយ ជា ឧទ្ទាម ដែល ហ៊ាន ប្រឆាំងនឹង ព្រះអង្គ ដើម្បី ដណ្តើម រាជ្យសម្បត្តិ ជា កាតព្វកិច្ច របស់ ព្រះអង្គ ដែល ជា តំណាង នៃ ឯកភាព ជាតិ និង ជា អ្នក រក្សា របៀបរៀបរយ ក្នុង ព្រះនគរ។ ដូច្នេះ អំពើ របស់ ព្រះសេរីរាជា ក្នុង នាម ព្រះអង្គ ជា មហាក្សត្រ ស្របច្បាប់ ជា អំពើ ត្រូវច្បាប់ ដ្បិទ វា ជា បុព្វសិទ្ធិ របស់ មហាក្សត្រ ដែល មាន ចែង ក្នុង ទេសធម៌ ជា ប្រពៃណី នៃ ក្សត្រខ្មែរ។ ជា សង្គ្រាម មាន មូលហេតុ ត្រឹមត្រូវ មាន ច្បាប់ ជា សំអាង ជា រាជសម្ភារៈ ស្វែង រក ឯកភាពជាតិ ផង និង ការទំនុក បម្រុង ប្រជារាស្ត្រ ក្នុង ព្រះនគរ តែមួយ អំណាច តែមួយ ផង ដើម្បី រក្សា សេចក្តី រៀបរយ សំរាប់ ការរស់នៅ រាល់ថ្ងៃ នៃ ប្រជារាស្ត្រ។

តែ ចំពោះ ព្រះអង្គ ផ្ទាល់ ទ្រង់ មាន បរាជ័យ ក្នុង ការរក្សា សេចក្តីរៀបរយ ក្នុង រាជវង្ស បណ្តោយ ឲ សង្គ្រាម ទាមទារ រាជបល្ល័ង្គ កើត មាន បាន ហើយ ខ្វះ មធ្យោបាយ ស័ក្តិសិទ្ធិ សំរាប់ រលត់ វិវាទ យោធា នោះ។ ការនេះ ជាការ ទទួល ខុសត្រូវ របស់ ព្រះអង្គ ក្នុង នាម ព្រះអង្គ ជា អ្នក

រក្សា សន្តិភាព ក្នុង ព្រះនគរ។ ទង្វើ របស់ ព្រះអង្គ ទោះ បី ជា អំពើ ស្របច្បាប់ យ៉ាង ណា ក៏ ដោយ ក៏ អាច ប្រជារាស្ត្រ ចោទ ប្រកាន់ ព្រះអង្គ ថា ជា ស្តេច ខ្វះ ទសពិធរាជធម៌ ព្រោះ ក្នុង នគរ មាន សង្គ្រាម ទាមទារ រាជបល្ល័ង្ក នាំ បំបែក ផែនដីខ្មែរ ជា តំបន់ អំណាច ខុសៗគ្នា ដែល ធ្វើ ឲ ប្រជារាស្ត្រ មាន ឧបសគ្គ ក្នុង ការធ្វើ ចរាចរណ៏ ដើម្បី ប្រកប របរ ចិញ្ចឹមជីវិត, គ្មានសន្តិសុខ ក្នុងការរស់នៅ, គ្មានសេចក្តីសុខ ក្នុង គ្រួសារ ព្រោះ សមាជិក នៃ គ្រួសារ ត្រូវ ស្តេច និមួយៗ កែន យក ទៅ ធ្វើ សង្គ្រាម បំរើ ប្រយោជន៏ អំណាច ព្រះអង្គ រៀងៗខ្លួន។

ស្តេច សៀម អាច ប្រើ ល្បិច បញ្ឆោត ព្រះសេរីរាជា បាន ងាយស្រួល ព្រោះ ស្តេច ខ្មែរ មាន គំនិត ស្រាល ហើយ គ្មាន ការប្រយ័ត្ន គ្មាន យុទ្ធសាស្ត្រ ច្បាស់លាស់ ជា ពិសេស យុទ្ធ សាស្ត្រ ការពារទុកជាមុន ឬ ការពារ សកម្ម គ្រប់ ពេល វេលា សំរាប់ ប្រឈរមុខ នឹង គ្រប់ស្ថានភាព ដែល អាច នឹងមាន កើតឡើង បាន។ គោលចំណង់ របស់ ព្រះសេរីរាជា គឺ នឹកស្មាន ក្នុង ចិត្ត ថា ព្រះអង្គ ជា ព្រះមហាក្សត្រ ខ្មែរ ស្របច្បាប់ ដូច្នេះ ដំណោះស្រាយ នៃ វិវាទខ្មែរ គឺ ច្បាស់ ជា គ្មាន នរណា នឹងលើក យក រាជ្យ របស់ ព្រះអង្គ មក សើរើ នោះឡើយ។ ទោះ បី ព្រះអង្គ យក គំនិត សន្តិភាព និយម មក ធ្វើ ជា គោលគំនិត ក្នុង ការសម្រេចចិត្ត

របស់ព្រះអង្គ តែ នៅ ក្នុង គំនិត បរាជ័យនិយម ដែល វា នាំ បង្វឹក ទឹកចិត្ត ព្រះអង្គ អោយ ក្លាយ ជា អ្នកកំសាក។ ភាពកំសាក នោះហើយ ដែល ជា បរាជ័យ ដាច់ខាត របស់ ព្រះអង្គ។

ត្រូវ ដឹង ថា នៅ ពេល ស្រុកខ្មែរ មាន សន្តិភាព ព្រះសេរីរាជា បង្កើត ទំនាស់ កំបាំង[3] ជាមួយនឹង ព្រះធម្មរាជា ដោយ មាន បារម្ភ ពី ការក្បត់ របស់ ព្រះអនុជ តាម ការ ញុះញង់ របស់ អ្នកអបអម របស់ ព្រះអង្គ។ អារម្មណ៍ នោះ ដែល នាំ មាន ការមិនទុកចិត្ត រវាង បងប្អូន ហើយ នាំ អោយ ព្រះធម្មរាជា ឆ្លៀត ឱកាស នៅ ពេល ឃើញ ព្រះរាម ចុះខ្សោយ មិន ព្រម ជួយ ព្រោះ បារម្ភ ដល់ពេល ព្រះរាម មាន កម្លាំង អំណាចមហាក្សត្រ ឡើងវិញ នឹងអាច យក ខ្លួន ធ្វើ ជា សត្រូវ រាជបល្ល័ង។

## កំហុស ព្រះស្រីសុរិយោទ័យ ?

ព្រះអង្គ ជា ឧទ្ទាម ជា អ្នក បង្ករបង្កើត ចលាចល ដល់ ជាតិ មាន ទុច្ចន្ទៈ ចង់ ដណ្តើម អំណាច នៅ ពេល ដែល នគរ កំពុង ធ្វើ សង្គ្រាមនឹង នគរសៀម នាំ ឲ បែក បាក់ កម្លាំង ជាតិខ្មែរ នៅ ចំពោះមុខ សត្រូវជាតិ។ ដូច្នេះ អំពើ របស់ ព្រះអង្គ ជា អំពើ ផ្តួយនឹង ប្រយោជន៍ជាតិ ជា អត្ត

[3] ទំនាស់ កំបាំង; conflit latent។

ទត្ថអំពើ ទុក ជាតិ ជា វត្ថុ ដែល ខ្លួន ប៉ង ចង់ បាន ដោយ យក សង្គ្រាម ជា មធ្យោបាយ ដើម្បី សំរេច ទំនើងចិត្តខ្លួន យកអំពើ ក្បត់ ជា សីលធម៌ ឥត ស្គាល់ សភាវៈ (ល្អ និង អាក្រក់) ស្គាល់ តែ មហិច្ឆិតា គ្មាន ព្រំដែន ដូច្នេះ ព្រះអង្គ ជា ជន ក្បត់ជាតិ និង សំបថ នៅ ចំពោះ មុខ មហាក្សត្រ ថា នឹង មាន ភក្តីភាព និង ការពារ ព្រះមហាក្សត្រ លុះ ដល់ សេចក្តី ស្លាប់។

យើង ឃើញ ថា ព្រះស្រីសុរិយោទ័យ ក៏ ដូច ព្រះសេរីរាជា ដែរ មាន គំនិត ស្រាល ចាញ់បោក ស្តេចសៀម ដោយសារ តែ មាន គំនិត ងប់ នឹង រាជបល្ល័ង ភ្លេច អស់ ដល់ គំនិត ជាតិនិយម។ ទ្រង់ ដឹង ថា ស្តេចសៀម ឃុំ ស្តេចខ្មែរ បែរ ជា មាន សេចក្តីត្រេកអរ នឹក ស្រម័យ ថា ខ្លួន នឹងឡើង គ្រង រាជ្យ បន្ត ពី ព្រះបិតុលា រី យ៉ាង ហោចណាស់ ស្តេចសៀម នឹងបែងចែក ស្រុកខ្មែរ ជា ពីរ មួយ ជា ផែនដី ព្រះជម្ពូរាជា មួយទៀត ជា ផែនដី របស់ខ្លួន។ មាយាការ (illusion) នេះ គឺ មាន នៅ ក្នុង គំនិត បរាជ័យនិយម ព្រោះ ទុក ស្តេចសៀម ជា អភិសិត្តរាជ (roi sacré) ជា អ្នក សំរួលការ នៃ បញ្ហា ផ្ទៃក្នុងខ្មែរ ដោយ គ្មាន គំនិត សង្ស័យ បន្តិចបន្តួច ថា វា អាច ជា ឧបាយសឹក សំរាប់ ផ្តាច់ កម្លាំងកាយ ដោយកម្លាំងប្រាជ្ញា ផ្តាញ់ មនុស្សភ្លៀវភ្លា ដោយ ការអង់អាច។ ស្តេចសៀម ផ្តាញ់ ព្រះស្រីសុរិយោទ័យ

បាន ដោយ មិន ចាំបាច់ ធ្វើ ចម្បាំង ព្រោះ ព្រះអង្គ យក កិត្យានុភាព ព្រះអង្គ ជា ស្តេច នគរ ធ្លាប់ តែ ឈ្នះ សង្គ្រាម លើ ស្រុកខ្មែរ តាំង ពី សតវត្ស ទី១៣ មក។ គួរ កត់សំគាល់ ថា ទឹកដី ប្រទេសសៀម ធ្លាប់ ជា ទឹកដី របស់ខ្មែរ ពិតមែន តែ តាំង ពី ទឹកដី ទាំងឡាយ នោះ ក្លាយ ជា នគរ ឯករាជ្យ ចាប់ ពី សតវត្ស ទី ១៣ នគរ សៀម មិន ដែល ចាញ់ សង្គ្រាម នឹង ស្រុកខ្មែរ នោះ ឡើយ ផ្ទុយ ទៅ វិញ នគរ សៀម តែងតែ វាយ ឈ្នះខ្មែរ ដើម្បី ពង្រីក ទឹកដីសៀម ជា និច្ច។ ជ័យជំនះ តន្ទើន[4] នោះ នាំ អោយ មហាក្សត្រខ្មែរ មាន ហីនមានៈ ចំពោះ មហាក្សត្រសៀម ហើយ លែង មាន គំនិត ធ្វើ ចម្បាំង នឹង សៀម ដើម្បី រំដោះ ទឹកដីខ្មែរ។ ករណី ព្រះសេរីរាជា លើក ទ័ព វាយ ចូល ទៅ ក្នុង នគរ សៀម ជា ការរៀបង់ (exception) មួយ តែ ដោយ អកុសល កងទ័ព ខ្មែរ គ្មាន សព្វាវុធ ទំនើប ដូចយ៉ាង កាំភ្លើងធំ ដែល នាំ អោយ ទ័ពខ្មែរ មិនអាច វាយ យក បន្ទាយ រាជធានីសៀម បាន។

## កំហុស ព្រះធម្មរាជា ?

ព្រះអង្គ ជា និមិត្តរូប នៃ គុណវិបត្តិ បំពួន ជា ផ្លែល្វា ផង ជា ផ្លែស្លែង ផង ព្រោះ សន្តិភាព ដែល ព្រះអង្គ យក បាន មក សំរាប់ ជាតិខ្មែរ ជា សន្តិភាព មាន ជាតិ ពិសពុល

44 តន្ទើន de façon répétée។

ព្រោះ ជា សន្តិភាព បង្ខំ តាម ឆន្ទះ សត្រូវជាតិ ក្នុង ពេល នោះ គឺ នគរ សៀម ដែល ស្តេចសៀម ទ្រង់ មាន បំណង តែ មួយ គត់ គឺ « សងសឹកនឹងខ្មែរ » និង ឆ្លៀត ឱកាស រក ប្រយោជន៍ក្នុង វិវាទ ផ្ទៃក្នុងខ្មែរ។ ព្រះអង្គ ជា ជនក្បត់ នឹង ព្រះរៀម ព្រះអង្គ និង រាជបល្ល័ង្គ ជា ជន ឱកាស និយម ឆ្លៀត រក អត្ថប្រយោជន៍ នៅ ពេល ដែល ព្រះស្រីសុរិយោទ័យ បង្កើត ដំបន់ អបគមន៍ ដែល ជា ការនាំ ឲ បាត់ ឯកភាពជាតិ។ ព្រះអង្គ មាន លទ្ធភាព អាច ជួយ ព្រះមហាក្សត្យ ដោយ យក កម្លាំង ទ័ព ព្រះអង្គ ទៅ រួម នឹង កម្លាំង ទ័ពហ្លួង ដើម្បី វាយ បង្ក្រាប ការបះបោរ បំបែក ឯកភាពជាតិ តែ ផ្ទុយទៅវិញ បែរ ជា បង្កើត ដំបន់ អបគមន៍ ប្រកាស ខ្លួន ជា មហាក្សត្យ ទី៣ ហើយ រក គ្រប់ មធ្យោបាយ ដើម្បី ដណ្តើម រាជបល្ល័ង្គ ទៅ ពឹង សៀម ដោយ យក ឈាម កូនកាត់ ជាតិសៀម របស់ខ្លួន ទៅ ប្រលោម ចិត្ត ស្តេចសៀម ឲ មក ជួយ ខ្លួន ទោះ បី ដឹង ច្បាស់ ថា ច្បាស់ ជា នឹង បាត់ ប្រយោជន៍ ដ៏ ច្រើន ដល់ ជាតិ។ ក្នុង ការស្នើ សូម ជំនួយ បរទេស នេះ ជា ពិសេស នៅ ក្នុង ជំនាន់ នោះ ទៅ សុំ ឲ សៀម ជួយ គឺ ដូច ជា បើក ទ្វារ នគរ ឲ សៀម ចូល មក យក ដីខ្មែរ ងាយ ស្រួល តែ ម្តង។ ទង្វើ នេះ នាំ ប្រគរ បញ្ហា លើ ជាតិខ្មែរ ដែល មាន សៀម ជា អ្នក ចំណេញ ដាច់មុខ ហើយ នាំ ប្រហែក ខ្មែរ និង ខ្មែរ និង ឲ មាន ប្រឡូកបប៉ុច្ឆា ក្នុង

សតិជាតិ។ ដូច្នេះ ព្រះធម្មរាជា ពុំ អាច មាន គុណសម្បត្តិ ជា ក្សត្រជោតិក[5] បាន នោះឡើយ។ មោហាគតិ[6] របស់ ព្រះអង្គ នាំ ៩ ជាតិ ធ្លាក់ ក្នុង ឥទ្ធិពល បរទេស ក្លាយ ជា ស្រុករណប សៀម ជំពាក់ គុណ សៀម។ ព្រះអង្គ ជា ជនក្បត់ជាតិ ស្មើភាពនឹង ព្រះស្រីសុរិយោទ័យ ហើយ មាន តែលើស ពី ព្រះស្រីសុរិយោទ័យ ព្រោះ ព្រះអង្គ ជា ជន យកការបោកប្រាស កុហក ខ្មែរ ជា ជាតិរួម នឹង ព្រះអង្គ ជាមធ្យោបាយ សំរាប់ រក ប្រយោជន៍ ផ្ទាល់ខ្លួន រស់នៅ ក្នុងគោលការណ៍ ដ៏ ក្រខ្វក់ គឺ « ប្រយោជន៍អញ ធំ ជាងប្រយោជន៍ជាតិ »។

ដូច្នេះ សន្តិភាព ដែល ព្រះធម្មរា ជា អ្នក បង្កើត បាននោះ គឺ ជា សន្តិភាព ដើម្បី រាជបល្ល័ង្ក របស់ ព្រះអង្គ ជាសន្តិភាព លក់ កិត្តិយសជាតិ ទោះ បី ក្នុង សន្តិភាព នោះអាច នាំ នូវ ឯកភាពជាតិ មក វិញ ក៏ ដោយ តែ ជាតិខ្មែរបាត់ បូរណភាព ទឹកដី ព្រោះ ខេត្ត ខ្មែរ ទាំងឡាយ នៅបែក ខាងលិច ដែល សៀម គេ បញ្ចូល ជា ឧបសម្ពន្ធ ក្នុងស្រុកសៀម ត្រូវ ព្រះធម្មរាជា ទទួល ស្គាល់ ជា ស្ថាពរ ថា ជាទឹកដីសៀម ពេញលេញ។ ឯកភាពជាតិ នោះទៀត គឺ ជាឯកភាព មាន ការប្រេះឆា ក្នុងចិត្ត រវាង ខ្មែរ នឹងខ្មែរព្រោះជា ឯកភាពជាតិ កើត មាន ពី វញ្ចការ (បោក

---

[5] ក្សត្រជោតិក; ក្សត្រមានសេចក្ដីរុងរឿង។
[6] មោហាគតិ; សេចក្ដី លម្អៀង បំពាក់ បំពាន ព្រោះ មិន យល់ ខុសត្រូវ។

ប្រាស) ពី សំណាក់ ភាគី មួយ ដែល ទៅ ពឹង កម្លាំងបរទេស ឲ ជួយ ជម្រុះជម្នះ ខ្លួន ដើម្បី បំរើ អត្ថប្រយោជន៍។ ជា សន្តិភាព នាំ ឲ ខ្មែរ គ្មាន មោទនភាព បន្តិច ណាឡើយ ព្រោះ សៀមគេ ចាប់ ស្តេចខ្មែរ យក ទៅ ស្រុកគេបាន ងាយ ស្រួល ដូច គេ បោចស្មៅ ដូច្នោះឯង នាំ ឲ ខ្មែរមាន ជវនចិត្ត[7] ថា ខ្លួន ជា ជាតិសាសន៍សុញ្ញ ចំពោះសត្រូវជាតិ។ សន្តិភាព បាន មក ពី កម្លាំងបរទេស គឺ ពិតជា សន្តិភាព ភេជ្ជរូប[8] សំរាប់ជាតិ ព្រោះ ក្រោយៗមក ស្តេចសៀម តែងតែ បន្ត វាយ ស្រុកខ្មែរ ជា និច្ច។ យើង ដឹងថា ការ ទៅ ពឹង សៀម ឲ ជួយ ក្នុង វិវាទ ផ្ទៃក្នុងខ្មែរ វា ក៏ក្លាយ ជា ទម្លាប់ របស់ រាជវង្សខ្មែរ តៗ មកទៀត។

សន្តិភាព ដែល ព្រះធម្មរាជា ទ្រង់ ទុក ជា បុញ្ញកិរិយា (ទង្វើ ដ៏ ល្អ) របស់ទ្រង់ ព្រោះ ព្រះអង្គ នាំ សេចក្តីសុខ ជូនប្រជារាស្ត្របាន អាច សួរ ថា តើ សេចក្តីសុខ នោះ ជា សេចក្តីសុខ បែបណា សំរាប់ ប្រជារាស្ត្រ ក្រោយ ពី បានបាត់បង់អស់ នូវ អ្វីៗ ដែល ជា ប្រគោល នៃ ជីវិត ក្នុង សង្គ្រាម រវាង រាជវង្ស បំផ្លាញ ជាតិ។ ព្រះធម្មរាជា ជា អ្នកដុត ភ្លើង សង្គ្រាមម្នាក់ដែរ ហើយ រក្សា ភ្លើង នោះ ឲ ឆេះយ៉ាងយូរ បំផុត ដើម្បី ឲ ផ្ទះខ្មែរ លែង មាន ស្លុំ (សសរ) សំរាប់ ទ្រទ្រង់ ដើម្បី ទ្រង់ ស្រួល ទៅ សូម ស្តេចសៀម ដែល

[7] ជវនចិត្ត: ចិត្តដែលស្ទុះទៅចាប់អារម្មណ៍។
[8] ភេជ្ជរូប: ដែលមិនជាប់បានយូរ។

ជា ខ្សែញាតិ ខាងមាតា របស់ទ្រង់ ឲ មក យក ជ័យជំនះ លើ ខ្មែរ សំរាប់ អំណាច របស់ ទ្រង់ តែប៉ុណ្ណោះ។

ទង្វើ របស់ ព្រះធម្មរាជា វា ក្លាយ ជា ទេសធម៌ សំរាប់ ព្រះរាជវង្សានុវង្ស ខ្មែរ គឺ នៅ ពេល ណា មាន វិវាទ រវាង គ្នានឹងគ្នា តែងតែ នាំ គ្នា ទៅ ពឹង បរទេស អោយ មក ជួយ ដោះស្រាយ បញ្ហា ផ្ទៃក្នុង របស់ញាតិ ដោយ ហ៊ាន សន្យា រហូត ទូទាត់ ដល់ អ្នក ជួយខ្លួន យក ប្រយោជន៍ជាតិ ជា រង្វាន់ មាន ទឹកដី ឯករាជ្យជាតិ និង អធិបតេយ្យភាពជាតិ តែម្តង។

## សេចក្តីសន្និដ្ឋាន

បើ យើង បាន អាន ឯកសារ លោក អេង សុត យើង ឃើញ ថា ក្នុង ឯកសារនោះ គ្មាន មាន ការវិនិច្ឆ័យ ទៅ លើ ហេតុការណ៏ ដែល មាន កើត ឡើង នោះ ឡើយ។ លោក ជា អ្នកប្រវត្តិសាស្ត្រ គ្រាន់ តែ លើក ព្រឹត្តិការណ៏ មក បង្ហាញ តែ មិនមែន មាន ន័យ ថា លោក គ្មាន គំនិត ចង់ បកស្រាយ ឲ ល្អិតល្អន់ ក្នុង ព្រឹត្តិការណ៏ ដែល លោក បាន សរសេរ នោះឡើយ ប៉ុន្តែ នៅ ក្នុង បរិការណ៏ខ្មែរ ជំនាន់ នោះ សេរីភាព មតិ ត្រូវ អ្នក កាន់អំណាច គេ ទុក ជា បទឧក្រិដ្ឋ ប្រឆាំង រដ្ឋ ឬ ជា បទឧក្រិដ្ឋ ប្រមាថ ព្រះមហាក្សត្រ។

ដូច យើង បាន ដឹង រួចហើយ ដែរ ថា អ្វី ដែល ជា ប្រវត្តិសាស្ត្រជាតិ គឺ ជា កម្មសិទ្ធិ របស់ អ្នកកាន់អំណាច អ្វី ដែល ជា មតិផ្ទុយ ពី និក្ខេបបទ ជា ផ្លូវការ គឺ ជា អវិជ្ជា ជា វិទ្ធង្សនា បំផ្លាញ ប្រយោជន៍ជាតិ។ នៅ ក្នុង ទស្សនៈ បែប នេះ យើង ជូន ជា មតិ ថា ប្រវត្តិសាស្ត្រ របស់ ជាតិ ខ្មែរ ដែល យើង បានអាន ក្តី បាន ឮ ក្តី មាន លក្ខណៈ ជា ព័តិមាន បោយយកប្រយោជន៍ ឬ ជា ការឃោសនា របស់ អ្នក កាន់អំណាច ច្រើន ជាង ជា ប្រវត្តិវិទ្យា ហេតុនេះឯង ចំពោះ យើង អ្នក អាន គួរ ត្រូវ មាន ការប្រយ័ត្ន គឺ កុំ អាន នឹងភ្នែក សំរាប់ គ្រាន់ ឲ មាន ការភើបចិត្ត តែ ត្រូវ យក សម្បជញ្ញ មក អាន ដើម្បី រក ការពិត សំរាប់ ទុក ជា មេរៀន សំរាប់ជាតិ។

ប្រវត្តិសាស្ត្រជាតិខ្មែរ ដែល អ្នកប្រាជ្ញ បរទេស បាន ស្រាវជ្រាវ យ៉ាង ល្អិតល្អត់ ដោយ យក វិជ្ជា វិទ្យាសាស្ត្រ ជា វិធី ក្នុង ការសិក្សា របស់គេ គឺ ពិត ជា មាន ការពិត ច្បាស់ នោះហើយ តែ អ្នកប្រាជ្ញ ទាំងនោះ គេ យក មក សរសេរ សំរាប់ ជូន ជា ព័តិមាន ជា បឋម ដល់ ជនជាតិគេ ឬ អ្នកចេះដឹង ក្នុង កំរិត ខ្ពស់មួយ និង ទុក ជា ការកត់ ចំណាំ សំរាប់ ការចេះដឹង នៃ មនុស្សជាតិ ដូច្នេះ ច្បាស់ ជា អ្នកអាន គេ យក មក ពិចារណា ជា និច្ច នូវ អ្វី ដែល គេ បាន អាន ព្រោះ អ្នកទាំងនោះ គេ មាន ទម្លាប់ ក្នុង វប្ប

ធម៌ របស់គេ គឺ គតិវិវេចនា[9] សំរាប់ រក ពន្លឺ សំរាប់ ការចេះដឹង របស់គេ។ គតិវិវេចនា នេះហើយ ដែល វា គ្មាន នៅ ក្នុង វប្បធម៌ខ្មែរ ព្រោះ ជាតិខ្មែរ រស់ នៅ ក្នុង របប សក្តិភូមិ របប ផ្តាច់ការ ជា និច្ច។

ការដឹងឮ ដោយ មិន បាន យក វា មក ធ្វើ ការពិចារណា មិន អាច ទុក ជា ការចេះដឹង បាន នោះឡើយ ហើយ ប្រាជ្ញាញាណ (ការកំណត់ដឹង) ណា ដែល មនុស្ស ម្នាក់ មាន នោះ ពុំ អាច ចាត់ ទុក វា ជា ជំនឿ ដាច់ខាត សំរាប់ ជន ម្នាក់ទៀត បាន នោះឡើយ។ ដូច មាន នៅ ក្នុង ពាក្យ ទូលមានខ្មែរ ថា « មនុស្ស កុំ មើល ងាយ មនុស្ស » ; « ប្រាជ្ញឯង អោយ ក្រែង ប្រាជ្ញគេ »។

**ថ្ងៃ ទី១ មីនា ឆ្នាំ ២០១៧**

[9] គតិវិវេចនា; esprit critique (គតិវិះគន់)។